# I- ទីស្តីការគណៈរដ្ឋមន្ត្រី

## អនុក្រឹត្យ

*រាជធានីភ្នំពេញ, ថ្ងៃទី ០៥ ខែ មេសា ឆ្នាំ ១៩៩៤*

**អនុក្រឹត្យលេខ ១៥ អនក្រ**

រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុវរ្ម័ន ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញតម្រូវការចាំបាច់ក្នុងការស្តារ និង កសាងប្រទេស

**សំរេច**

**មាត្រា ១ :** បង្កើតមេដាយស្ថាបនាជាតិ និង ប័ណ្ណស្ថាបនាជាតិ ដើម្បីជូនដល់សប្បុរសជនកម្ពុជា ទាំងក្នុងប្រទេស និង ក្រៅប្រទេស ឬ ជនបរទេស ជាបុគ្គល ឬ ជាសមូហភាព ដែលបានធ្វើភាគទានជាថវិកា ឬ សំភារៈក្នុងការរួមចំណែកស្ថាបនា ប្រទេសជាតិឡើងវិញ ។

**មាត្រា ២ :** មេដាយស្ថាបនាជាតិមាន ៣ ថ្នាក់ គឺ ថ្នាក់លេខ ១ ពណ៌មាស ថ្នាក់លេខ ២ ពណ៌ប្រាក់ និង ថ្នាក់លេខ ៣ ពណ៌ លង្ហិន ។ លក្ខខ័ណ្ឌសំរាប់ប្រគល់ជូនមេដាយស្ថាបនាជាតិមានដូចតទៅ :

១- សប្បុរសជនដែលបានធ្វើអំណោយជូនរដ្ឋ ជាថវិកា ឬ សំភារៈមានតំលៃលើសពីដប់ម៉ឺនដុល្លារអាមេរិក ( US$ 100.000 ) ឡើងទៅ ត្រូវបានជូនមេដាយស្ថាបនាជាតិថ្នាក់លេខ ១ និង ត្រូវបានរាជរដ្ឋាភិបាលស្នើសុំព្រះរាជយោបល់ដ៏ខ្ពង់ខ្ពស់ នៃ ព្រះករុណាជាអម្ចាស់ជីវិតដ៏តល់លើត្បូង ដើម្បីទ្រង់ព្រះរាជទានគោរមងារជា " ឧកញ៉ា " ។

២_ សប្បុរសជនដែលបានធ្វើអំណោយជូនរដ្ឋ ជាថវិកា ឬ សំភារៈមានតំលៃ ចាប់ពីមួយ ម៉ឺន ដុល្លារអាមេរិកដល់ ដប់ម៉ឺនដុល្លារអាមេរិក ( US$ ១០.០០០. US$ 100.000 ) ត្រូវបានជូនមេដាយស្ថាបនា ។

៣_ សប្បុរសជនដែលបានធ្វើអំណោយជូនរដ្ឋ ជាថវិកា ឬ សំភារៈមានតំលៃចាប់ពីប្រាំ ពាន់ដុល្លារអាមេរិក ដល់ មួយម៉ឺនដុល្លារអាមេរិក ( US$ 5.000 . US$ 10.000 ) ត្រូវបានជូនមេដាយស្ថាបនាជាតិថ្នាក់លេខ ២ ។

៤_ សប្បុរសជនដែលបានធ្វើអំណោយជូនរដ្ឋជាថវិកា ឬ សំភារៈមានតំលៃ ចាប់ពីមួយពាន់ដុល្លារអាមេរិកដល់ប្រាំ ពាន់ដុល្លារអាមេរិក ( US$ ១,000 US$ 5, 000 ) ត្រូវបានជូនមេដាយស្ថាបនាជាតិថ្នាក់លេខ ៣ ។

មេដាយស្ថាបនាជាតិ ត្រូវបានសំរេចដោយអនុក្រឹត្យរបស់រាជរដ្ឋាភិបាលកម្ពុជា ។

**មាត្រា ៣ :** ប័ណ្ណស្ថាបនាជាតិសំរាប់ជូនចំពោះសប្បុរសជន ដែលបានធ្វើអំណោយជូនរដ្ឋជាថវិកា ឬ សំភារៈមានតំលៃ ចាប់ពី ប្រាំរយដុល្លារអាមេរិក ដល់មួយពាន់ដុល្លារអាមេរិក ( US$ 500 - US$ ១.000 ) ។ ប័ណ្ណស្ថាបនាជាតិត្រូវបានសំរេច ដោយសេចក្តីសំរេចរបស់ទីស្តីការគណៈរដ្ឋមន្ត្រី ។

**មាត្រា ៤ :** គ្រប់ក្រសួង ស្ថាប័ន រដ្ឋលេខាធិការដ្ឋាន និង ខេត្ត ក្រុង ក្រោយពេលបានទទួលអំណោយពីសប្បុរសជនជាទឹកប្រាក់ ឬ សំភារៈដូច មានចែងក្នុងមាត្រា ២ និង មាត្រា ៣ ត្រូវធ្វើសំណើ មកទីស្តីការគណៈរដ្ឋមន្ត្រី ដោយភ្ជាប់មកជាមួយ នូវឈ្មោះម្ចាស់អំណោយទឹកប្រាក់ និងមុខសញ្ញាដែលត្រូវប្រើប្រាស់អំណោយនៅក្នុងមូលដ្ឋានរបស់ខ្លួន ដើម្បីរាជរដ្ឋាភិបាលពិនិត្យ និង សំរេច ។

**មាត្រា ៥ :** សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីគ្រប់ក្រសួង រដ្ឋលេខាធិការ គ្រប់រដ្ឋលេខាធិការដ្ឋានអភិបាលគ្រប់ខេត្ត ក្រុងត្រូវទទួលអនុវត្តអនុក្រឹត្យនេះអោយមាន ប្រសិទ្ធភាពល្អ ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និងចុះហត្ថលេខា តទៅ ។

| | |
|---|---|
| នាយករដ្ឋមន្ត្រី ទី ១ | នាយករដ្ឋមន្ត្រី ទី ២ |
| ព្រះហស្តលេខា និងត្រា | ហត្ថលេខា និង ត្រា |
| **នរោត្តម រណឫទ្ធិ** | **ហ៊ុន សែន** |

***